គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ
បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
Regulate, Supervise, and Develop Trust Sector
in the Kingdom of Cambodia

និយ័តករបរធនបាលកិច្ច
Trust Regulator

លេខ ១៥ ចេញផ្សាយថ្ងៃទី១១ ខែតុលា ឆ្នាំ២០២១
No. 15 Released on October 11, 2021

# អត្ថបទប្រចាំសប្ដាហ៍ | Weekly Article

## ការចុះបញ្ជីបរធន | Trust Registration




រូបភាព | Picture: https://www.shutterstock.com/image-vector/registration-form-vector-register-554234929

បរធនបាលកិច្ចទាំងអស់មានសុពលភាព លុះត្រាតែចុះបញ្ជីនៅនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ក្នុងរយៈពេលមិនលើសពី**៣ (បី)** ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការបង្កើតបរធនបាលកិច្ច។ លក្ខខណ្ឌនិងនីតិវិធីលម្អិតនៃការចុះបញ្ជី ត្រូវកំណត់ដោយអនុក្រឹត្យស្ដីពីការចុះបញ្ជីបរធនបាលកិច្ច។ មុននឹងធ្វើការចុះបញ្ជីសម្រាប់ប្រតិបត្តិករបរធន-បាលកិច្ចនៅ **ន.ប.ធ.** ស្របតាមមាត្រា២៨នៃច្បាប់ស្ដីពីបរធនបាលកិច្ច (២០១៩) ការបង្កើតបរធនបាលកិច្ចដើម្បីគោលបំណងណាមួយនៃច្បាប់នេះ ត្រូវមានការអនុញ្ញាតជាគោលការណ៍ជាមុនពី**ន.ប.ធ.**/បញ្ញត្តិករពាក់ព័ន្ធ។ ការធ្វើប្រតិបត្តិការនៃបរធនបាលកិច្ចស្របតាមគោលបំណងនៃច្បាប់ស្ដីពីបរធនបាលកិច្ចត្រូវមានអាជ្ញាបណ្ណ/ការអនុញ្ញាតពី **ន.ប.ធ.**/បញ្ញត្តិករពាក់ព័ន្ធស្របតាមបទប្បញ្ញត្តិដែលមានជាធរមាន។ **ន.ប.ធ.** មានកាតព្វកិច្ចកត់ត្រា គ្រប់គ្រង និងរក្សាទុកនូវរាល់ព័ត៌មានរបស់បរធនបាលទាយក, បរធនបាល, អត្ថគាហកៈ, បុគ្គលផ្សេងទៀតដែលពាក់ព័ន្ធ, ប្រតិវេទន៍ប្រចាំឆ្នាំ, ការផ្លាស់ប្ដូរបរធនបាល និងព័ត៌មានចាំបាច់ផ្សេងៗពាក់ព័ន្ធនឹងការចុះបញ្ជី។ លក្ខខណ្ឌនិងនីតិវិធីធ្វើប្រតិវេទន៍ប្រចាំឆ្នាំ និងសេចក្ដីជូនដំណឹងពីការផ្លាស់ប្ដូរបរធនបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុម-ប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។

All trusts are valid only if they are registered with the Trust Regulator (**TR**) within **3 months** after the date of the establishment of the trust. The detailed conditions and procedures for registration shall be determined by the sub-decree on the trust registration. Prior to registration for trust operator at the **TR** pursuant to Article 28 of the Law on Trust (2019), the establishment of trust for any purpose of this law requires prior approval in principle from the **TR**/ relevant regulator. The operation of trust in accordance with the purpose of the law on trust must be licensed/ authorized by the **TR**/ relevant regulator in accordance with the provisions in force. The **TR** has obligation to record, manage and keep all the information of the trustors, the trustees, the beneficiaries, the other persons involved, the annual reform, the change of trustee and other necessary information related to the registration. The conditions and procedures for the annual reform and the notification of the change of trustee shall be determined by a Prakas of the Minister of Economy and Finance and Chairman of the Board of Non-Bank Financial Services Authority (**NBFSA**).

**អត្ថបទ៖ ណង សេរីវុធ | Article: Sereyvuth Nong**

**ឯកសារយោង | References**:

- មាត្រា២៨, ២៩, &៣០, ច្បាប់ស្ដីពីបរធនបាលកិច្ច. (២០១៩).
- ច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ. (២០២១).

ប្រកាសបដិសេធ÷ ទស្សនៈនៅក្នុងអត្ថបទនេះជាទស្សនៈរបស់អ្នកនិពន្ធ។ ទស្សនៈនៅក្នុងអត្ថបទនេះមិនមែនជាទស្សនៈរបស់និយ័តករបរធនបាលកិច្ចទេ។
Disclaimer: The opinions expressed in this article are those of the authors. They do not purport to reflect the opinions or views of the Trust Regulator.